សុន្ទរកថារបស់**លោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ**

ភារៈធារីស្ដីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយ

សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៧ កុម្ភៈ ២០១៣

- **សូមគោរព លោក ងី សែត ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្ដីសោមនស្សរីករាយដែលបានចូលរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយជាមួយតំណាងរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តបាត់ដំបងសម្រាប់គម្រោងសាងសង់អគារសិក្សាថ្មីក្នុងសាលាបឋមសិក្សាយុត្តិធម៌ និង សាលាបឋមសិក្សាសំណាងព្រះស្រី។ ខ្ញុំក៏មានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងដែលការចុះហត្ថលេខានេះត្រូវបានធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ដែលជាខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅកែលម្អបរិស្ថានអប់រំសម្រាប់សាលាបឋមសិក្សាចំនួនពីរក្នុងតំបន់ដាច់ស្រយាលនៃស្រុកបវេលតាមរយៈការសាងសង់អគារសិក្សា និង បរិក្ខារអនាម័យ ព្រមទាំងអាងស្តុកទឹកផងដែរ។ ថវិកាជំនួយដែលផ្ដល់ជូនសម្រាប់គម្រោងនេះមានចំនួន១២២,៧៧១ដុល្លាអាមេរិក។ អគារសិក្សាឈើនៅក្នុងសាលាបឋមសិក្សាទាំងពីរនេះមានសភាពចាស់ទ្រុឌទ្រោមដែលធ្វើឲ្យសិស្សានុសិស្សមានការលំបាកក្នុងការយកចិត្តទុកដាក់លើការរៀនសូត្ររបស់ពួកគេនៅក្នុងថ្នាក់រៀន។ តាមរយៈការកែលម្អបរិក្ខារសិក្សានេះ យើងរំពឹងថាគម្រោងនេះនឹងផ្ដល់អត្ថប្រយោជន៍ដល់សិស្សានុសិស្សប្រមាណ៧៨០នាក់ដែលកំពុងសិក្សាក៏ដូចជាកុមារដែលនឹងត្រូវចូលរៀនក្នុងសាលាបឋមសិក្សាទាំងពីរនេះនាពេលអនាគត។

ការអប់រំ និង អភិវឌ្ឍន៍ធនធានមនុស្សជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍន៍ប្រទេសកម្ពុជានាពេលអនាគត។ ដោយហេតុនេះហើយ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាពខ្ពស់ទៅលើវិស័យអប់រំដោយចាត់ទុកជាមុំមួយក្នុងបណ្ដាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណសម្រាប់អភិវឌ្ឍន៍ជាតិ។ ជាមួយគ្នានេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងខិតខំប្រឹងប្រែងបង្កើនចំនួនសាលាបឋមសិក្សាដើម្បីឈានដល់គោលដៅនៃការផ្ដល់ការអប់រំកម្រិតបឋមសិក្សានៅទូទាំងប្រទេសត្រឹមឆ្នាំ២០១៥។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យអប់រំសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ចក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្ដល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការផ្ដល់ជំនួយទាំងផ្នែកសម្ភារៈ និងផ្នែកបច្ចេកទេស។ គម្រោងនេះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលការណ៍ជាមូលដ្ឋាននៃជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្ដល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខាថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន និង ប្រកបដោយប្រសិទ្ធភាពព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដោយដៃគូរបស់យើងគឺ មន្ទីរអប់រំ យុវជន និង កីឡាខេត្តបាត់ដំបងដើម្បីសិស្សានុសិស្សកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។ សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់!